ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ២៦៥

ចុះថ្ងៃទី១៣ខែកក្កដាឆ្នាំ១៩៩៨

សាលដីកា

លេខ : ៨០

ចុះថ្ងៃទី២៣ខែមេសាឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះ ជាសាធារណៈ នៅថ្ងៃទី ២៣ - ខែ មេសា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :-

១-ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២-លោក ប៊ិន ស៊ិន ជាចៅក្រម

៣-លោក សៀល ទូន ជាចៅក្រម

៤-លោក ឈឹម ស៊ីផល ជាចៅក្រមរបាយការណ៍

៥-លោក ជីវ កេង ជាចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី ឃុត សុគន្ធា

តំណាងមហាអយ្យការ

លោក ប៊ិន សារវឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ២៤១ ចុះថ្ងៃទី ២៥-០៥-៩៨ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ៧១៤ ចុះថ្ងៃទី ២៥-១២-៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ញ៉ាវ អេង ភេទ ប្រុស អាយុ ៣៦ ឆ្នាំ ជាតិខ្មែរ ទីលំនៅ នៅភូមិ-ឃុំ ស្វាយដូនកែវ ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ ឪពុកឈ្មោះ ញ៉ាំង ស៊ុង "ស" ម្តាយ-ឈ្មោះ សាត់ អឿន "រ" ប្រពន្ធឈ្មោះ ផាន់ ផល្លី ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ អ៊ុំ សុគន្ធី ភេទ ស្រី អាយុ ៣១ ឆ្នាំ ជាតិខ្មែរ មុខរបរ-មេផ្ទះ ទីលំនៅភូមិពាលញ៉ែត១ ឃុំផ្ទះព្រៃ ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ ។ ឪពុកឈ្មោះ-អេង ណឹងវ៉ន "ស" ម្តាយឈ្មោះ ងួន មឿន "រ" ប្រពន្ធឈ្មោះ ឈឹម សៀ ។

តាមបណ្តឹងសាទុក្ខលេខ ២៧៦ ចុះថ្ងៃទី ១៥-៧-៩៨ របស់លោក ញ៉ាវ អេង ប្តឹងមិនសុខចិត្ត នឹងសាលដីកាលេខ ២៤១ ចុះថ្ងៃទី ២៥-០៥-៩៨ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៦៥ ចុះថ្ងៃទី ១៣-០៨-៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ២១-៦-៩៦ របស់ឈ្មោះ អ៊ុំ សុគន្ធី ប្តឹងសុំអោយឈ្មោះ ញ៉ាវ អេង-

រុះរើផ្ទះចេញពីដីភូមិរបស់ខ្លួន ដោយហេតុថាដីភូមិនោះឈ្មោះ អ៊ីវ នាង និង ប្រពន្ធឈ្មោះ -អ៊ីវ ទេង បានយកមកដាក់បញ្ចាំចងការមាសពីខ្លួនតាំងពីឆ្នាំ ១៩៩៣ ។ លុះអ្នកទាំងពីរ រកការប្រាក់ និង ដើមសងខ្លួនវិញពុំបាន ក៏ព្រមព្រៀងលក់ដីនេះមកអោយខ្លួន ដោយអោយថែមមាសទម្ងន់ ៥ជីទៀតបង្គ្រប់តម្លៃដី ៥តម្លឹង ១ ជី ដោយមានធ្វើលិខិតផ្ទេរ លក់ត្រឹមត្រូវតាមច្បាប់ ។ ចំណែកឯឈ្មោះ ញ៉ាវ អេង ពុំព្រមរុះរើផ្ទះរបស់ខ្លួនចេញពីដីនោះទេ ។

បានឃើញសាលក្រមលេខ ៦៥ ចុះថ្ងៃទី ២៩-៨-៩៧ របស់តុលាការខេត្តពោធិ៍សាត់ ដែលសម្រេចដូចតទៅ :-

១-ក. ទទួលពាក្យបណ្ដឹងចុះថ្ងៃទី២១-៦-៩៧ របស់ឈ្មោះ អ៊ីវ សុគន្ធី ប្ដឹងសុំអោយឈ្មោះ ញ៉ាវ អេង រុះរើផ្ទះចេញពីដីកម្មសិទ្ធិរបស់ខ្លួនដែលបានទិញពីឈ្មោះ អ៊ីវ នាង ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

ខ. ទទួលសំណូមពរនាពេលសវនាការរបស់ដើមចោទសុំអោយចុងចម្លើយ ចេញការប្រាក់អោយខ្លួន ក្នុងករណីមិនព្រមរុះរើផ្ទះចេញ ដោយមូលហេតុខ្លួនត្រូវចេញការប្រាក់ជារៀងរាល់ខែ នៃ មាសថ្លៃដីនោះ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ក. អោយឈ្មោះ ញ៉ាវ អេង រុះរើផ្ទះចេញពីដីកម្មសិទ្ធិរបស់ឈ្មោះ អ៊ីវ សុគន្ធី ដែលបានទិញពីឈ្មោះ អ៊ីវ នាង ចាប់ពីថ្ងៃសាលក្រមចូលស្ថាពរ ។

ខ. ករណីឈ្មោះ ញ៉ាវ អេង រឹងរូសអូសបន្លាយពេលមិនព្រមរុះរើផ្ទះចេញ ត្រូវទទួលបន្ទុកចេញការប្រាក់អោយទៅឈ្មោះ អ៊ីវ សុគន្ធី ក្នុង១ខែ ៥ភាគរយនៃ មាសថ្លៃដី និង ផ្ទះទម្ងន់ ៥ តម្លឹង គិតចាប់ពីថ្ងៃផុតកំណត់ប្ដឹងឧទ្ធរណ៍ ។

៣- បង្គាប់អោយឈ្មោះ ញ៉ាវ អេង បង់ប្រាក់ប្រដាប់ក្ដីគឺ :-

- ពន្ធចុះបញ្ជីក្ដី និង ពន្ធតឹងចំនួន ១.៨០០៛០០
- រង្វាន់ក្រឡាបញ្ជីតាន់តឹបប្រាក់ចំនួន ២០០៛០០
- ចំណាយក្នុងការវាស់ដីការកោះ ចំនួន៥.០០០៛០០

សរុប ៧.០០០៛០០ ប្រាក់នេះបានគាត់យកពីដើមចោទ ដែលបានបង់រួចហើយ កាលបើសាលក្រមចូលស្ថាពរ ត្រូវប្រគល់ប្រាក់នេះ អោយដើមចោទវិញ ។

និងអោយបង់ពន្ធសមាមាត្រ ១ភាគរយ នៃតម្លៃដីវង្វង់ផ្ទះបន្ថែមទៀត ដោយដាក់ជាថវិការដ្ឋចំនួន ៨០ភាគរយ និង ដាក់តឹបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេសចំនួន ២០ភាគរយ កាលបើសាលក្រមចូលស្ថាពរ ។

តាមច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដី ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃ-០៨-០២-៩៣ ។

៤- សាលក្រមនេះជំនុំជម្រះជាសាធារណៈ ចំពោះមុខគូក្ដី ។ បើកផ្លូវប្ដឹងឧទ្ធរណ៍រយៈពេល ២ ខែ គិតចាប់ពីថ្ងៃនេះ ។

សាលក្រមនេះត្រូវបានឈ្មោះ ញ៉ីវ អេង ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ២៤ ចុះថ្ងៃទី ១៦-៤-៨៦ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីកាលេខ ២៤១ ចុះថ្ងៃទី ២៥-៥-៨៨ របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៦-៤-៨៨ របស់ឈ្មោះ ញ៉ីវ អេង ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- បដិសេធចំណុចទី ២ នៃ សេចក្តីសំរេចរបស់សាលក្រមលេខ ៦៥ ចុះថ្ងៃទី ២៤-៨-៨៦ របស់តុលាការខេត្តពោធិ៍សាត់ ចោលជាអសារបង់ និង សំរេចជាថ្មីដោយបង្គាប់អោយឈ្មោះ - ញ៉ីវ អេង រុះរើផ្ទះចេញពីដីទំនាស់ចាប់ពីសាលក្រមចូលជាស្ថាពរ ។ ចំណុចក្រៅពីនេះតំកល់ទុកជាបានការដដែល ។

៣- កាត់ឈតប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រ០០ ដែលដើមបណ្តឹងបានបង់រួចហើយគឺ :- ពន្ធចុះបញ្ជីក្តី និង ពន្ធតាំងចំនួន ២.៥៥០រ០០ រង្វាន់ក្រឡាបញ្ជីតាមតិបប្រាក់ចំនួន- ៤៥០រ០០ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រ០០ និង លើអាជ្ញាធរតុលាការចំនួន - ៥.០០០រ០០ សរុប ១៣.០០០រ០០ ។

៤- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៧៦ ចុះថ្ងៃទី ១៥-៦-៨៨ របស់លោក ញ៉ីវ អេង ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាការពារចុះថ្ងៃទី ០៥-១០-៨៨ របស់ឈ្មោះ ញ៉ីវ អេង ។

បានឃើញសារណាតបចុះថ្ងៃទី ២៦-១០-៨៨ របស់ឈ្មោះ អ៊ីវ សុគន្ធី ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :- សាលដីការដ្ឋប្បវេណីលេខ ២៤១ ចុះថ្ងៃទី ២៥-៥-៨៨ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទម្រង់-ទាំងគតិច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ ញ៉ីវ អេង ដែលបានឆ្លើយនៅពេលសវនាការថា :- ឆ្នាំ១៩៨២ ឪពុកចិញ្ចឹមខ្លួនបានផ្ទេរសិទ្ធិមកអោយខ្លួន រឿងលក់នោះមិនពិតទេ គឺ ថែមឈ្មោះលើប្រាក់ជំពាក់ ហើយចុះចេញ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ អ៊ីវ សុគន្ធី ដែលបានឆ្លើយនៅពេលសវនាការថា:- អេង ថាឱ្យខ្លួនទិញទៅ ចាំតែទិញពីខ្លួនវិញព្រោះខ្ញុំទិញពីឈ្មោះ អ៊ីវ នាង ខ្លាចគាត់មិនចុះ ដែនពេលខ្លួនទិញបានប្រាប់អោយទិញតែគាត់មិនទិញ ។ តានាងក៏បានសារភាពថាគាត់មិនបានប្រគល់ដីអោយ

ញ៉ាវ សេង ទេ ដីនេះគាត់លក់អោយនាងគន្ធីហើយ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុ លា កា រ កំ ពូ ល

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ ២៧៦ ចុះថ្ងៃទី ១៥-៧-១៩៩៨ របស់លោក - ញ៉ាវ សេង ជាចុងចម្លើយធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះ បានតាមមាត្រា ១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថាលោក ញ៉ាវ សេង បានទទួលស្គាល់ថាដីទំនាស់នេះ ជាដីរបស់លោក អ៊ុំ នាង ពិតប្រាកដមែន ហើយបាននឹងថាលោក អ៊ុំ នាង បានលក់ផ្តាច់អោយទៅលោក- យឹម សៀ រួចហើយ ពុំមានហេតុដែលខ្លួនពុំព្រមរើផ្ទះចេញពីដីនេះ ព្រោះលោក អ៊ុំ នាង នៅជំពាក់ប្រាក់លោក ។

- យល់ឃើញថាបញ្ហាជំពាក់ប្រាក់ គឺជាវិវាទមួយផ្សេងទៀត តបើលោក ញ៉ាវ សេង ប្តឹងទាមទារអោយលោក អ៊ុំ នាង សងប្រាក់ជំពាក់មកខ្លួនវិញនោះ ទើបត្រឹមត្រូវ ។

- យល់ឃើញថាលោក ញ៉ាវ សេង បានអះអាងថាដីនេះលោក អ៊ុំ នាង បាន ប្រគល់មកអោយខ្លួនដោយមានលិខិតប្រគល់ដី ប៉ុន្តែលិខិតនេះ ត្រូវបានលោក អ៊ុំ នាង ជា- ម្ចាស់ដីព្រមទាំងសាក្សីផង បានបដិសេធចោលទាំងស្រុង ។

- យល់ឃើញថាលិខិតទិញ-លក់ដីរវាងលោក អ៊ុំ នាង និង លោក យឹម សៀ មាន លក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ។

- យល់ឃើញថាសាលដីការដ្ឋប្បវេណីលេខ ២៤១ ចុះថ្ងៃទី ២៥-០៥-១៩៩៨ របស់ សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងអង្គច្បាប់ហើយ ។

ហេ តុ ដូ ច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ២៧៦ ចុះថ្ងៃទី ១៥-៧-៩៨ របស់លោក ញ៉ាវ សេង ទុក ជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងអង្គច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ២៤១ ចុះថ្ងៃទី២៥-៥-១៩៩៨ របស់ សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៥.០០០រ៛០០ ដែលអ្នកស្រី អ៊ុំ សុគន្ធី បានបង់ជំនួស រួចហើយគឺ :-

- ពន្ធផឹង និង ពន្ធបញ្ញាត្តិចំនួន ៥.០០០៛០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛០០ សម្រាប់ផារង្វាន់ក្រមប្រាបញ្ញាការទឹបប្រាក់ ។

- ចំណាយលើកិច្ចប្រគល់ដីការកោះ ចំនួន ១៥.០០០៛០០ សរុប ១៩.០០០៛០០ ហើយ តម្រូវអោយលោក ញៀវ អេង សងប្រាក់ចំនួន ១៨.០០០៛០០នេះ ទៅអ្នកស្រី អ៊ុំ សុគន្ធី វិញ ។

បង្គាប់អោយលោក ញៀវ អេង បង់ពន្ធសមាមាត្រ១ភាគរយ លើតម្លៃជាក់ស្តែង នៃ ដីទំនាស់ ។

៥_ សាលដីការនេះ ប្រកាសជាសាធារណៈ នាសវនាការនៅថ្ងៃទី ២៧ _ ខែ មេសា ឆ្នាំ ១៩៩៩ ។